ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨៨៧
ចុះថ្ងៃទី២៥.០៧.២០១៨
សាលដីកា
លេខ: ១២១ ក្រVI.ត.ស
ចុះថ្ងៃទី២៩.១១.២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ភ្នំពេញនាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមាន ៖

**<u>សមាសភាពក្រុមប្រឹក្សា</u>**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

[redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ៨៨៧ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] **សំអាត** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងសិប្បកម្ម មានទីកន្លែងកំណើតនៅភូមិព្រៃកប្រា សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។ **<u>ប្តឹងឧទ្ធរណ៍</u>**

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ២០១/១៧ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧។

២-ជនជាប់ចោទឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងសិប្បកម្ម មានទីកន្លែងកំណើតនៅភូមិថ្មគោល ឃុំថ្មគោល ស្រុកថ្មគោល ខេត្តបាត់ដំបង មានទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន។ **<u>ប្តឹងឧទ្ធរណ៍</u>**

-ឃុំខ្លួន[illegible]លេខ: ២០៣/១៧ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧។

៣-ជន[illegible] [redacted] [illegible] ហៅ ញុាំញ់, ចិន ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិជ្រូវ[illegible] ឃុំ[illegible] ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ





Scanned with CamScanner

[redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូនចំនួន ០៤នាក់ ជាទីតិជន ទោសពីមុនគ្មាន។ **ប្តឹងឧទ្ធរណ៍**

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខៈ **៨៩/២០១៧** ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧។

មានមេធាវី [redacted] **ម៉ារ៉ាឌី** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងបីនាក់ខាងលើ។

៤-ជនជាប់ចោទឈ្មោះ [redacted] **ម៉េង** ហៅ [redacted] **ផាន់ធី** ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើត នៅភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ មានទីលំនៅបច្ចុប្ប[redacted] ជាំក្សាន្ត ខេត្តព្រះវិហារ ឪពុកឈ្មោះ[redacted] (ស) ម្តាយឈ្មោះ[redacted](រ) នៅលីវ ជាទីតិជន ទោសពីមុនគ្មាន។ **(ក្រៅឃុំ)**

ជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង១១ និង៤០នាទី កម្លាំងអធិការដ្ឋាននគរបាលស្រុកជាំក្សាន្ត បានចុះធ្វើការបង្ក្រាប និងឆែកឆេរករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅភូមិជាំក្សាន្ត ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ បង្កឡើងដោយជនសង្ស័យខាងលើ ត្រូវសមត្ថកិច្ចដកហូតបាននូវវត្ថុតាងរួមមាន សារធាតុញៀនប្រភេទមេតំហ្វេតាមីនម្សៅពណ៌ស (ម៉ាទឹកកក) ចំនួន ០១កញ្ចប់ធំ និង០៥កញ្ចប់តូច មានទម្ងន់ ១០៧,៣១ ក្រាម ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១ រថយន្តកាមេរីពណ៌សំបកឪឡឹកចំនួន ០១គ្រឿង ពាក់ស្លាកលេខភ្នំពេញ 2A-7624 ទូរស័ព្ទដៃចំនួន ០២គ្រឿង លុយដុល្លារចំនួន ៤៧៤ដុល្លារអាមេរិក លុយខ្មែរចំនួន ១៤,000,000៛ កាំភ្លើងខ្លីចំនួន ០១ ដើម និងគ្រាប់កាំភ្លើងចំនួន ០១គ្រាប់ កាំបិតចំនួន០២ និងពូថៅចំនួន០១ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួនទៀត មកជាមួយពិតប្រាកដមែន។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខៈ **០៧ "ខ"** ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រះវិហារ ដែលបានសម្រេចថា ៖

១./ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សំអាត** ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **ម៉េង** ហៅ [redacted] **ផាន់ធី** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **យអេង** ហៅ **ញ៉ាំញ់, ចិន** ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ១០ (ដប់)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០ (ម្ភៃ) លានរៀល ក្នុងម្នាក់ៗ ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ តាមមាត្រា **៤០** កថាខណ្ឌ ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២./វត្ថុចាប់យកមានម្សៅក្រាមពណ៌សថ្លាមានចំនួន ០១កញ្ចប់ធំ និង ០៥កញ្ចប់តូច មានទម្ងន់ ១០៧,៣១ ក្រាម, ប្រាក់រៀលចំនួន ១៤,000,000 (ដប់បួនលាន)រៀល, ប្រាក់ដុល្លារចំនួន ៤៧៤ (បួនរយចិតសិបបួន) ដុល្លារ,



Scanned with CamScanner

រថយន្តម៉ាកកាមេរីពណ៌សំបកខីឡឹក ស៊េរីឆ្នាំ១៩៩៥ ពាក់ស្លាកលេខភ្នំពេញ 2A-7624 ចំនួន ០១គ្រឿង (មានសោ), កាំភ្លើងខ្លីលេខ S1366 ចំនួន ០១ដើម (ខូច) និងគ្រាប់ចំនួន ០១គ្រាប់, ទូរស័ព្ទម៉ាកណូគាពណ៌ខ្មៅ (ចុចពិល) ចំនួន ០២គ្រឿង, អត្តសញ្ញាណប័ណ្ណឈ្មោះ [redacted] សំអាត ចំនួន០១, កាត Angkor Tep Group ចំនួន០១, កាំភ្លើងកែច្នៃចំនួន ០១ដើម, កាំបិតវែងចំនួន ០២ដើម, សៀវភៅចុះបញ្ជីលក់ថ្នាំញៀនចំនួន ០១ក្បាល, កាបូបខ្មៅពណ៌ខ្មៅចំនួន០១, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១ (គ្មានថ្ម), ថង់សំរាប់ច្រកថ្នាំញៀនចំនួន ០១កញ្ចប់ធំ, ស្កុរក្រាមចំនួន ០១ប្រអប់, សាជូរ ចំនួន ០១កញ្ចប់ធំ, ប្រអប់ដាក់ថ្នាំញៀនចំនួន ០១ប្រអប់, កំប៉ុងដាក់ថ្នាំញៀនចំនួន០១, ឧបករណ៍ធ្វើតេស្តទឹកនោម ចំនួន ០២, វិក័យប័ត្រវីងចំនួន ១០សន្លឹក និងសម្ភារៈប្រើប្រាស់ថ្នាំញៀនចំនួន ០១កញ្ចប់ធំ ត្រូវរឹបអូសតាមមាត្រា **៦២** នៃក្រមព្រហ្មទណ្ឌ។

៣./សាលក្រមជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សំអាត** ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **មួយអេង** ហៅ **ញ៉ាំញ់ ចិន** ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ម៉េង** ហៅ [redacted] **ដាវ៉ន៍ធី** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ បើភាគីណា មិនសុខចិត្តនឹងសេចក្តីសម្រេចនេះមានសិទ្ធិប្តឹងទាស់, ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**-បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអាត**, ជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌ លេខ: ០៧ “ខ” ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុច **នៃសេចក្តីសម្រេចទាំងមូល**។

**-បានឃើញ** របាយការណ៍រឿង ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## <u>**នាពេលសវនាការ**</u>

-ជនជាប់ចោទឈ្មោះ [redacted] **សំអាត** (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] **សំណាង** (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ហៅ **ញ៉ាំញ់ ចិន** (វត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ម៉ាភ័ធី** (វត្តមាន)

-ប្រធានក្រុមប្រឹក្សា អានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] **សំអាត** បានឆ្លើយសារភាពនាពេលសវនាការថា: ខ្លួនសុំឆ្លើយសារភាពថាគ្រឿងញៀនដែលសមត្ថកិច្ចដកបាននោះជារបស់ខ្លួន មិនមែនរបស់ [redacted] **សំណាង** ទេ។ ថ្នាំញៀននោះខ្លួនទិញមកសម្រាប់ប្រើប្រាស់ ទិញក្នុងតម្លៃ ៨០០$ (ប្រាំបីរយ)ដុល្លារអាមេរិក។ តាមចម្លើយរបស់ខ្លួនកន្លងមកខ្លួនមិនទទួលស្គាល់ថាថ្នាំ



Scanned with CamScanner

ញៀននោះជារបស់ខ្លួនទេ ដោយសារខ្លួនភ័យពេកទើបខ្លួនឆ្លើយថាគ្រឿងញៀននោះជារបស់ [redacted] សំណាង ពេលដែលគេចាប់បាននោះគេឱ្យខ្លួនផ្តិតមេដៃទទួលស្គាល់គ្រឿងញៀនខ្លួនក៏ផ្តិតដោយសារខ្លួនភ័យពេក។ កន្លងមកខ្លួនមិនធ្លាប់ឆ្លើយទទួលស្គាល់គ្រឿងញៀនជារបស់ខ្លួនទេ។

សំណូមពរ ស្នើសុំឱ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់ខ្លួនផង ព្រោះខ្លួនបានដឹងខ្លួនខុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] **សំណាង** បានឆ្លើយសារភាពនាពេលសវនាការថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះគឺដោយសារសាលាដំបូងផ្តន្ទាទោសខ្លួនច្រើនពេក។ ខ្លួនសុំទទួលស្គាល់នូវចម្លើយរបស់ខ្លួនកន្លងមក ប៉ុន្តែខ្លួនសុំឆ្លើយបញ្ជាក់ថាបានជានៅពេលដែលសមត្ថកិច្ចចាប់នោះខ្លួនឆ្លើយថាថ្នាំញៀននោះជារបស់ខ្លួន ព្រោះសមត្ថកិច្ចបានគំរាមខ្លួនថាប្រសិនបើគ្មានអ្នកណាទទួលស្គាល់ថ្នាំញៀននោះទេ គាត់នឹងចាប់ទាំងប្រពន្ធនិងកូនរបស់ខ្លួនមកដែល ដោយខ្លួនអាណិតកូននិងប្រពន្ធ ទើបខ្លួនឆ្លើយទទួលស្គាល់ថាថ្នាំញៀននោះជារបស់ខ្លួនតែម្តងដើម្បីឱ្យប្រពន្ធនិងកូនរបស់ខ្លួនរួចខ្លួន ប៉ុន្តែការពិតថ្នាំញៀននោះមិនមែនជារបស់ខ្លួនទេ គឺជារបស់ឈ្មោះ [redacted] **សំអាត**។ សមត្ថកិច្ចបានដកហូតគ្រឿងញៀននៅផ្ទះរបស់ឈ្មោះ [redacted] **សំអាត** ចំណែកខ្លួនជាជាងសិប្បកម្មដែលទៅធ្វើឱ្យគាត់។

សំណូមពរ ស្នើសុំឱ្យក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់ខ្លួន ដើម្បីឱ្យខ្លួនបានចូលទៅក្នុងសង្គមធ្វើជាពលរដ្ឋល្អផង។

-ជនជាប់ចោទឈ្មោះ[redacted]**យអេង** ហៅ **ញ៉ាំញ់ ចិន** បានឆ្លើយបដិសេធនាពេលសវនាការថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះគឺដើម្បីស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់ដល់ខ្លួនផង ព្រោះខ្លួនមិនមានពាក់ព័ន្ធក្នុងរឿងនេះទេ គេចាប់ខ្លួនមកពន្ធនាគារគឺរឿងផ្សេងទេ។ ខ្លួនត្រូវជាអតីតប្រពន្ធរបស់ឈ្មោះ[redacted] **សំណាង** កាលពីជាង ១០ឆ្នាំមុន។ សមត្ថកិច្ចបានចុះទៅចាប់ខ្លួននៅខាងត្រពាំងបី ដោយខ្លួនទៅទិញដីគេនៅទីនោះ។ ពេលដែលគេចាប់ពួកគាត់នោះខាង ២០០៨ គេចាប់ខ្លួនមកខាងពន្ធនាគារខេត្តព្រះវិហារ ហើយនៅពេលដែលគេកាត់ទោសពួកគាត់ស្រាប់តែគេហៅខ្លួនទៅដែល ហើយខាងសាលាដំបូងគ្រាន់តែសួរថាខ្លួនត្រូវជាអ្វីជាមួយឈ្មោះ[redacted] **សំណាង**? ខ្លួនក៏បានឆ្លើយថាខ្លួនធ្លាប់ជាប្តីប្រពន្ធនឹងគ្នា ប៉ុន្តែពួកខ្លួនបានលែងលះគ្នាជាង ១០ឆ្នាំមកហើយ គឺបានគ្នាតាំងពីឆ្នាំ១៩៩៩ តែអត់មានកូនជាមួយគាត់ទេ ហើយខ្លួនបានលែងលះជានៅក្នុងឆ្នាំ២០០២ ចាប់តាំងពីថ្ងៃលែងលះគ្នាមកពួកខ្លួនមិនធ្លាប់ជួបគ្នា ឬប្រាស្រ័យទាក់ទងជាមួយគ្នាទៀតទេ រហូតដល់ខ្លួនមានប្តីថ្មី និងមានកូន០៣នាក់ទៀត ខ្លួនទើបតែបានជួបគាត់នាពេលសវនាការនៅសាលាដំបូង។ ខ្លួនព្រមទទួលស្គាល់នូវចម្លើយដែលខ្លួនបានឆ្លើយកន្លងមកទេ ព្រោះខ្លួនមិនបានរកស៊ីលក់គ្រឿងញៀនទេ។ ខ្លួនសុំបញ្ជាក់ថាពេលដែលខ្លួនចូលទៅពន្ធនាគារបាន ០១ខែភ្លាម ក៏មានគេថាខ្លួនជាប់ឈ្មោះជាមួយឈ្មោះ [redacted]**ណារិទ្ធ** ហើយគេកាត់កំបាំងមុខ ០៣ឆ្នាំទៀត ហើយខ្លួនមិនសុខចិត្ត ខ្លួនក៏បានឱ្យមន្ត្រីខាងពន្ធនាគារហៅឈ្មោះ[redacted]**ណារិទ្ធ** នោះមកសួរតទល់ ហើយបានធ្វើលិខិតប្តឹងជំទាស់ទៅខាងសាលាដំបូង ហើយខ្លួនមិនបានស្គាល់ម្នាក់ដែលឆ្លើយទម្លាក់ដាក់ឈ្មោះ **ញ៉ាញ់** ដែលចោទថាជាខ្លួននោះទេ ហើយពេលខ្លួនសួរគាត់ថាស្គាល់ខ្លួនអត់? គាត់ក៏ឆ្លើយថាមិនស្គាល់ទេ។ ហើយពេលខាងមន្ត្រីពន្ធនាគារបញ្ជាក់សួរគាត់ថាឈ្មោះ **ញ៉ាញ់** នោះរូបរាងយ៉ាងមិច? គាត់ក៏បានរៀបរាប់ថាឈ្មោះ **ញ៉ាញ់** នោះមិនមែនខ្លួនទេ គឺគាត់ខ្មៅ ហើយសក់ក្រញ៉ាញ់ទៀត។

សំណូមពរ ស្នើសុំឱ្យក្រុមប្រឹក្សាសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។



Scanned with CamScanner

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពិនិត្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងបីរូប ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។ ឃើញថាសារធាតុញៀនដែលដកបានពីជនជាប់ចោទដែលមានទម្ងន់ ១០៧ ក្រាម ដែលមានកម្រិតភាពសុទ្ធចំនួន ៨៣ ក្រាម ស្ថិតក្នុងកំណត់ច្បាប់នៃការផ្តន្ទាទោសពី ១០ឆ្នាំ ទៅ ២០ឆ្នាំ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអាត** និងជនជាប់ចោទឈ្មោះ [redacted] **សំណាង** អាចយកជាផ្លូវការបាន ព្រោះគាត់បានឆ្លើយថាថ្នាំញៀននោះពិតជាដកហូតនៅផ្ទះរបស់ជនជាប់ចោទពិតប្រាកដមែន ប៉ុន្តែចំពោះចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ឃើញថាមានការប្រែប្រួល និងមានចោទប្រកាន់តាមអំណាចផ្លូវច្បាប់ពីជនជាប់ចោទដែលជាប់ពន្ធនាគារថាគាត់បានទិញថ្នាំញៀនពីឈ្មោះ [redacted] **មួយអេង** ពិតប្រាកដមែន តាមការសាកសួររបស់ក្រុមប្រឹក្សា តំណាងមហាអយ្យការយល់ឃើញថាមិនមានភស្តុតាងដែលជាចម្លើយអនុវត្តព្យាករណ៍នោះទេ។ តំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាពិចារណាពីលទ្ធភាពអំពីការពិន័យ និងការបន្ធូរបន្ថយ ចំពោះការសម្រេចទៅនឹងការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ដែលគេដាក់គាត់ពីបទ រក្សាទុកថ្នាំញៀន ព្រោះបណ្តឹងឧទ្ធរណ៍ឋិតនៅក្នុងកំណត់ច្បាប់ហើយ ចំពោះការសម្រេចបែបណាតំណាងមហាអយ្យការមិនមានជំទាស់នឹងសាលាឧទ្ធរណ៍ភ្នំពេញទេ ចំណែកចំណុចក្រៅពីនេះតំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាតម្កល់ទុកដដែល។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអាត**, ជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ធ្វើសេចក្តីសន្និដ្ឋានថា: ស្តាប់តាមការសួរដេញដោលឃើញថាជនជាប់ចោទឈ្មោះ [redacted] **សំអាត** និងឈ្មោះ [redacted] **សំណាង** គាត់បានសារភាពទទួលស្គាល់ថាគ្រឿងញៀននោះជារបស់គាត់ពិតមែន ហើយការប្រព្រឹត្តរបស់គាត់នេះគឺឃើញថាជាការប្រព្រឹត្តដោយខ្វះការគិតពិចារណា ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ឃើញថាតាមការឆ្លើយបញ្ជាក់របស់ឈ្មោះ [redacted] **ណារិទ្ធ** ដែលបានឆ្លើយនៅពន្ធនាគារ ប៉ុន្តែនៅពេលដែលឈ្មោះ [redacted] **ណារិទ្ធ** ឆ្លើយបញ្ជាក់នៅចៅក្រមស៊ើបគឺគាត់បានឆ្លើយបញ្ជាក់ថាគាត់មិនបានស្គាល់ឈ្មោ[redacted] **មួយអេង** និងមិនដែលបានទិញគ្រឿងញៀនពីឈ្មោះ [redacted] **មួយអេង** នោះទេ ឃើញថាចម្លើយរបស់សាក្សីនេះមានការប្រែប្រួលមិនច្បាស់លាស់ ដែលបង្កើតបានជាវិមតិសង្ស័យលើជនជាប់ចោទរូបនេះ ម្យ៉ាងទៀតតាមការបញ្ជាក់របស់ជនជាប់ចោទឈ្មោះ [redacted] **មួយអេង** គឺគាត់បានឆ្លើយបញ្ជាក់ថាគាត់បានលែងលះជាមួយជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងមានគ្រួសារថ្មី រស់នៅកន្លែងផ្សេង ហើយនៅថ្ងៃបង្ក្រាបរបស់សមត្ថកិច្ចជនជាប់ចោទឈ្មោះ [redacted] **មួយអេង** មិនបានស្ថិតនៅកន្លែងបង្ក្រាបរបស់សមត្ថកិច្ចនោះទេ។ ដូចនេះខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាពិចារណាដោយសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] **មួយអេង** រួចផុតពីបទចោទ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] **សំអាត** និងជនជាប់ចោទឈ្មោះ [redacted] **សំណាង** ស្នើសុំឱ្យក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយដល់គាត់មួយផ្នែក។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអាត**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សំណាង**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **មួយអេង ហៅ ញ៉ាញ់ ចិន**

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងបីនាក់

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាឧទ្ធរណ៍ភ្នំពេញ</u>
## <u>យល់ឃើញថា</u>

១.ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអាត**, ជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ០៧ “ខ” ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុច **នៃសេចក្តីសម្រេចទាំងមូល** ធ្វើឡើងក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទទួលសំណុំរឿងខាងលើនេះជំនុំជម្រះបាន យោងតាមមាត្រា **៤៣** នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, មាត្រា **៣៧៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា **៣៨២ថ្មី** នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧, មាត្រា ៣៦៨, មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២.**តាមលទ្ធផលនៃកិច្ចពិភាក្សាសួរដេញដោលខាងលើ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា: តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអាត** និងជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ: **១០១៨៩/១៧ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលដកហូតបានពីជនជាប់ចោទទាំងពីររូបទទួលបានលទ្ធផលថ្នាំញៀនប្រភេទមេតំហ្វេតាមីនដែលមានកម្រិតភាពសុទ្ធ $\frac{107,31g \, x \, 78,10}{100} = 83,80g$ ដែលជាភស្តុតាងបង្ហាញឱ្យឃើញនូវអំពើឧក្រិដ្ឋប្រព្រឹត្តជាក់ស្តែង និងមានពិរុទ្ធភាពលើជនជាប់ចោទទាំងពីររូបខាងលើពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលបំពានមាត្រា ៤០ កថាខណ្ឌទី៦ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ រីឯជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ថាខ្លួនពុំបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺគ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌតែប៉ុណ្ណោះ ប៉ុន្តែចម្លើយបដិសេធនេះពុំមានភស្តុតាងយកមកបញ្ជាក់ ដើម្បីឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញអាចជឿបានឡើយ។ តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ណារិទ្ធ** ដែលកំពុងជាប់ពន្ធនាគារខេត្តព្រះវិហារ ដែលបានឆ្លើយថាគាត់បានទិញថ្នាំញៀនពីឈ្មោះ [redacted] **មួយអេង** ហៅ **ញ៉ាញ់** ហៅ **ចិន** ដែលជាប្រពន្ធរបស់ឈ្មោះ [redacted] **សំអាត** ដោយគេយកមកឱ្យតាមផ្លូវ តម្លៃ ១០០,០០០៛ (ដប់ម៉ឺន)រៀល ជាច្រើនដង ហើយក៏មិនបានដឹងថាឈ្មោះ [redacted] **មួយអេង** បានថ្នាំញៀនមកពីណាទេ។ ឈ្មោ[redacted]**ណារិទ្ធ** បានទាក់ទងទិញថ្នាំញៀនតាមរយៈលេខទូរស័ព្ទ [redacted] លេខទូរស័ព្ទរបស់ឈ្មោះ [redacted] **មួយអេង** ដែលជាភស្តុតាងបង្ហាញឱ្យឃើញនូវអំពើឧក្រិដ្ឋប្រព្រឹត្តជាក់ស្តែង និងមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលបំពានមាត្រា ៤០ កថាខណ្ឌទី៦ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញប្រកាសផ្តន្ទាទោសជនជាប់ចោទទាំងបីរូបនេះតាមច្បាប់ ដូចមានលើកឡើងនៅក្នុងផ្នែកសំអាងហេតុ នៃសាលក្រមព្រហ្មទណ្ឌលេខ: ០៧ “ខ” ចុះថ្ងៃទី២៣ ខែ



Scanned with CamScanner

មេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះវិហារបានបញ្ជាក់ស្រាប់ សាលាឧទ្ធរណ៍ភ្នំពេញឯកភាពតាមសំអាងហេតុខាងលើនេះ សាលាឧទ្ធរណ៍ភ្នំពេញពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតឡើយ ។

៣.តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានដោយសំណូមពរថា: ស្នើសុំឱ្យក្រុមប្រឹក្សាពិចារណាពីលទ្ធភាពអំពីការពិន័យ និងការបន្ធូរបន្ថយ ចំពោះការសម្រេចទៅនឹងការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ដែលគេដាក់គាត់ពីបទ រក្សាទុកថ្នាំញៀន ព្រោះបណ្តឹងឧទ្ធរណ៍ឋិតនៅក្នុងកំណត់ច្បាប់ហើយ ចំពោះការសម្រេចបែបណាតំណាងមហាអយ្យការមិនមានជំទាស់នឹងសាលាឧទ្ធរណ៍ភ្នំពេញទេ ចំណែកចំណុចក្រៅពីនេះ តំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាតម្កល់ទុកដដែល។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណាទៅតាមច្បាប់។

៤.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអាត**, ឈ្មោះ [redacted] **សំណាង** និងឈ្មោះ [redacted] **មួយអេង** បានធ្វើសេចក្តីសន្និដ្ឋានដោយសំណូមពរថា: ស្នើសុំឱ្យក្រុមប្រឹក្សាពិចារណាដោយសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] **មួយអេង** រួចផុតពីបទចោទ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] **សំអាត** និងជនជាប់ចោទឈ្មោះ [redacted] **សំណាង** ស្នើសុំឱ្យក្រុមប្រឹក្សាមេត្តា បន្ធូរបន្ថយដល់គាត់មួយផ្នែក។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ពិចារណាទៅតាមច្បាប់។

៥.សាលក្រមព្រហ្មទណ្ឌលេខ: ០៧ "ខ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះវិហារ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមអង្គហេតុនិងអង្គច្បាប់ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញសម្រេចតម្កល់សាលក្រមខាងលើនេះ ទុកជាបានការដដែល ដោយពុំមានការបន្ធូរបន្ថយទោសឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអាត**, ឈ្មោះ [redacted] **សំណាង** និងឈ្មោះ [redacted] **មួយអេង** ឡើយ ពីព្រោះសាលាដំបូងខេត្តព្រះវិហារបានសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីរូបខាងលើមានលក្ខណៈត្រឹមត្រូវតាមកម្រិតភាពសុទ្ធនៃសារធាតុញៀនហើយ។

## **ហេតុដូច្នេះ**
## **វិនិច្ឆ័យសេចក្តី**

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអាត**, ជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងជនជាប់ចោទឈ្មោះ [redacted] **មួយអេង** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ០៧ "ខ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការដដែល។

៣.បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **សំអាត**, ឈ្មោះ [redacted] **សំណាង** និងឈ្មោះ [redacted] **មួយអេង** តាមនីតិវិធីច្បាប់។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១។



Scanned with CamScanner

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា

[redacted] | [redacted] | [redacted]

បានផតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សាលាឧទ្ធរណ៍,ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]